NATIONAL AIDS AUTHORITY

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# លិខិតថ្វាយព្រះពរ

## សូមក្រាបបង្គំទូលថ្វាយ
## សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
## ព្រះវររាជមាតាជាតិ ជាទីគោរពសក្ការៈ

ក្នុងឱកាសចម្រើនព្រះជន្មគម្រប់៧៩ យាងចូល៨០ព្រះវស្សារបស់សម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និង សុភមង្គល ទូលព្រះបង្គំជាខ្ញុំ ភរិយា បុត្រា បុត្រី ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមព្រះបរមរាជានុញ្ញាតបួងសួង ដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក សូមថ្វាយសព្ទសាធុការពរបវរសួស្តី សិរីមង្គល មហាប្រសើរចំពោះសម្ដេច ព្រះមហាក្សត្រី សម្ដេចម៉ែ ដើម្បីទ្រង់មានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ព្រះរាជសុខភាពបរិបូណ៌ ព្រះរាជកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា និង គង់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រ ជាកូនចៅ ចៅទួតរបស់ព្រះអង្គជាដរាបរៀងទៅ ។

ទូលព្រះបង្គំយើងខ្ញុំ ជាកូនចៅព្រះអង្គ សូមព្រះរាជានុញ្ញាតក្រាបបង្គំទូលថ្វាយនូវកតញ្ញុតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតចំពោះព្រះមហាករុណាទិគុណដ៏ធំធេង ដែលសម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ បានប្រោសប្រទានដល់ប្រជារាស្ត្រជាកូនចៅព្រះអង្គ តាមរយៈព្រះរាជបេសកកម្មចូលរួមជាមួយព្រះករុណាព្រះបរមរតនកោដ្ឋ ការពារយ៉ាងរឹងមាំនូវឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដីក្នុងកាលកន្លងមក និង តាមរយៈព្រះរាជសកម្មភាពផ្ទាល់ព្រះអង្គផ្នែកសង្គមកិច្ច វប្បធម៌ដ៏ថ្លៃថ្លាបំផុត ដែលព្រះអង្គកំពុងបំពេញយ៉ាងសកម្មនៅពេលនេះ។

គួរពុំគួរសូម **សម្ដេចព្រះមហាក្សត្រី** ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ៕

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង មូលី**

អាសយដ្ឋាន ៖ អគារលេខ១៦ ផ្លូវលេខ ២៧១កែង១៥០ សង្កាត់ទឹកល្អក់II ខណ្ឌទួលគោក ទូរស័ព្ទ/ទូរសារ ៖ (៨៥៥) ២៣ ៨៨៥ ១២៩